ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

សារជូនពរ
សូមគោរពជូន
ឯកឧត្តមកិត្តិឧទ្ទេសបណ្ឌិត ប៉ុល សារ៉ឿន ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ
នៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីបម្រើនៅឆ្នាំយុគម្រប់ ៧៦ ឈានចូល ៧៧ឆ្នាំ

ឯកឧត្តមកិត្តិឧទ្ទេសបណ្ឌិត ជាទីគោរពជ្រះថ្លា!

ក្នុងឱកាសដ៏មហានក្ខត្តឫក្ស ប្រកបដោយក្តីរីករាយជាទីបំផុត ក្នុងពិធីបម្រើនៅឆ្នាំយុគម្រប់ ៧៦ ឈានចូល ៧៧ឆ្នាំ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃអាទិត្យ ៨រោច ខែស្រាពណ៌ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២៥ ខាងមុខនេះ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទ ខ្ញុំបាទនិងភរិយា សូមជូននូវសេចក្តីសាធុការពរដ៏ល្អ ស៊ីមង្គល ប៉ិលសុខ មហាប្រសើរ ជូន **ឯកឧត្តមកិត្តិឧទ្ទេសបណ្ឌិត** សូមទទួលបាននូវសុខភាពល្អបរិបូរ៉ កម្លាំងកាយមាំមួន ឫទ្ធានុភាពណាវ៉ា ជន្មាយុយឺនយូរ ដើម្បីបន្តរួមចំណែកជួយរាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍប្រទេសជាតិឱ្យកាន់តែខ្លាំងក្លា និងរីកចម្រើនរុងរឿង។

នាឱកាសដ៏មហាប្រសើរនេះ យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវសេចក្តីគោរពដ៏ស្មោះស្ម័គ្រ និងដឹងគុណជានិច្ចចំពោះគុណូបការៈ និងគំរូកំណែលរបស់ **ឯកឧត្តមកិត្តិឧទ្ទេសបណ្ឌិត** ដែលកន្លងមកតែងបានបំពេញបេសកកម្មធំៗជាច្រើន ជាពិសេសក្នុងវិស័យការពារជាតិប្រកបដោយតតិបណ្ឌិត និងបានលះបង់កម្លាំងកាយចិត្តប្រាជ្ញា ស្មារតី ក្នុងការបម្រើជាតិមាតុភូមិឱ្យទទួលបាននូវសុខសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍលើគ្រប់វិស័យ។

ជាចុងក្រោយទៀត តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងកងយោធពលខេមរភូមិន្ទទាំងមូល ខ្ញុំបាទនិងភរិយា សូមបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ និងតេជៈសក្តិសិទ្ធិទាំងឡាយក្នុងលោក មានទេវតាថ្នាក់ថ្មី សូមព្រះអង្គតាមជួយបីបាច់ថែរក្សាការពារ និងប្រោះព្រំនូវសេចក្តីសាធុការពរជ័យ ជូនចំពោះ: **ឯកឧត្តមកិត្តិឧទ្ទេសបណ្ឌិត** និង**លោកជំទាវ** ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី ជាទីស្រឡាញ់ សូមបានសមប្រកបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តមកិត្តិឧទ្ទេសបណ្ឌិត ប៉ុល សារ៉ឿន ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃសុក្រ ១៤កើត ខែស្រាពណ៌ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ សីហា ឆ្នាំ២០២៥

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

នាយឧត្តមសេនីយ៍ ទៀ សីហា

វិថីហ្សក៥ សង្កាត់មិត្តភាព ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ទូរស័ព្ទលេខ០២៣ ៨៨៣ ២១២៤ email: generalsec@mod.gov.kh

អរគុណសន្ធិភាព! អរគុណនយោបាយឈ្នះឈ្នះ!